# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ

ភាគីដាក់ឯកសារ: ក្រុមមេធាវីការពារក្តីលោក នួន ជា

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០១១

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 21-Jul-2011, 13:10
CMS/CFO: Kauv Keoratanak

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ សាធារណៈ/Public

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

## សារណារឆ្លើយតបទៅនឹងការសន្និដ្ឋានរបស់ កសព ទាក់ទងនឹងការទទួលយកកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សី

__ដាក់ដោយ៖__

**ក្រុមមេធាវីការពារក្តី នួន ជា**

សុន អរុណ

Michiel PESTMAN
Victor KOPPE
Andrew IANUZZI
Jasper PAUW

ព្រុំ ផល្លា

Annebrecht VOSSENBERG

សាស្ត្រាចារ្យ Michael RAMSDEN

__ផ្ញើជូន៖__

**ក្រុមមេធាវីការពារក្តីទាំងអស់**

សហព្រះរាជអាជ្ញា

លោកស្រី ជា លាង

លោក Andrew CAYLEY

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី:**

SULZER Jeane
Megan KARSH

# I. សេចក្ដីផ្ដើម

១. អនុលោមតាមការបង្គាប់របស់អង្គជំនុំជម្រះនេះ[1] មេធាវីការពារក្ដី នួន ជា (ក្រុមមេធាវីការពារក្ដី) តទៅនេះសូមដាក់សារណាឆ្លើយតបរបស់ខ្លួនទៅនឹងសេចក្ដីសន្និដ្ឋានតាមវិធាន ៩២ របស់សហព្រះរាជអាជ្ញា ទាក់ទងនឹងការទទួលយកកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្ដាប់ចម្លើយសាក្សីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង[2] (សេចក្ដីសន្និដ្ឋានសាក្សី) ដោយការិយាល័យសហព្រះរាជអាជ្ញា(កសព) ។ សម្រាប់មូលហេតុដែលបានបញ្ជាក់ដូចខាងក្រោម មេធាវីការពារក្ដីសូមស្នើឲ្យពិចារណាថា (ក) សក្ខីកម្មរបស់បដិសាក្សីដែលមានទាំងអស់ដែលមិនទាន់បានតទល់ដោយ នួន ជា ត្រូវតែបានស្ដាប់ដោយផ្ទាល់មាត់នៅសវនាការលើអង្គសេចក្ដីដោយគ្មានការលើកលែង, (ខ) កំណត់ហេតុជាលាយអក្ខណ៍អក្សរនៃការស្ដាប់ចម្លើយសាក្សីអាចទទួលយកបាន ជំនួសឲ្យសក្ខីកម្មផ្ទាល់មាត់នៅក្នុងករណីជាក់លាក់មួយចំនួនដោយមានលក្ខខណ្ឌ, និង (គ) បន្ទាប់ពីពិគ្រោះយោបល់ជាមួយសហព្រះរាជអាជ្ញា នួន ជា អាចលះបង់សិទ្ធិរបស់គាត់ក្នុងការតទល់ជាមួយសាក្សីដែលផ្ដល់សក្ខីកម្មទាក់ទងនឹងបទល្មើស(crime-base) ។

# II. សារណាឆ្លើយតប

## ក. ច្បាប់កម្ពុជាអនុញ្ញាតឲ្យស្ដាប់សក្ខីកម្មផ្ទាល់មាត់នៅសវនាការនៃបដិសាក្សីទាំងអស់ដែលមិនត្រូវបានតទល់ដោយជនជាប់ចោទ

២. កសព បានលើកអំណះអំណាងថាជនជាប់ចោទនៅ អវតក "មិនមានសិទ្ធិដាច់ខាតដើម្បីកោះហៅ និងសាកសួរសាក្សីនៅសវនាការឡើយ" ហើយបានលើកឡើងថាអង្គជំនុំជម្រះអាច "ប្រើឆន្ទានុសិទ្ធិរបស់ខ្លួន" តាមវិធីផ្សេងៗនៅពេលដោះស្រាយសក្ខីកម្មនៃបដិសាក្សីជាក់លាក់[3]។ ទាក់ទងនឹងចំណុចនេះ កសព ជម្រុញឲ្យមានការអនុម័តយន្តការនីតិវិធីមួយចំនួនដែលត្រូវបានបង្កើតឡើងនៅតុលាការអន្តរ

---

[1] សូមមើលឯកសារលេខ E-107 "សេចក្ដីសម្រេចជាសាធារណៈ ស្ដីពីការបន្ថែមពេលវេលាកំណត់" ចុះថ្ងៃទី ៧ ខែ កក្កដា ឆ្នាំ ២០១១ ERN 00711953–00711954 ។

[2] ឯកសារលេខ E-96, សារធារណៈចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១១ ERN 00706071–00706086 ។

[3] សូមមើលសេចក្ដីសន្និដ្ឋានសាក្សី នៅកថាខណ្ឌទី២ ។

ជាតិផ្សេងៗ[4] ។ ប៉ុន្តែសេចក្ដីសន្និដ្ឋានសាក្សីមិនអើពើចំពោះអង្គហេតុដែលថា ច្បាប់កម្ពុជាដែលនៅជាធរមានមានចែងយ៉ាងច្បាស់លាស់ និងគ្រប់គ្រាន់ពីបញ្ហានៃការយកសក្ខីកម្មរបស់បដិសាក្សី ហើយ កសព ខកខានមិនបានធ្វើយុត្តិកម្មចំពោះការងាកចេញដែលបានស្នើឡើងពីនីតិវិធីដែលត្រូវបានបង្កើតឡើងនោះទេ[5] ។

## ១. ច្បាប់កម្ពុជាដែលនៅធរមាន ចែងពីបញ្ហានៃសក្ខីកម្មរបស់បដិសាក្សី

៣. មាត្រា ២៩៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាចែងយ៉ាងច្បាស់ថា: "សាក្សីខាងដាក់បន្ទុកដែលមិនទាន់បានសួរចម្លើយតទល់គ្នាជាមួយជនជាប់ចោទ ត្រូវតែកោះហៅឲ្យចូលរួមក្នុងសវនាការ" (តាមពិតប្រយោគភាសាខ្មែរ *ត្រូវតែកោះហៅ* គឺមានសង្កត់ន័យ)។ វិធាន ៨៤(១) ស្របគ្នាជាមួយជំហរនេះ "ជនជាប់ចោទមានសិទ្ធិស្នើសុំឲ្យកោះហៅសាក្សីដាក់បន្ទុកដែលជនជាប់ចោទមិនទាន់មានឱកាសតទល់នៅដំណាក់កាលមុនពេលជំនុំជម្រះ ។ បទបញ្ញត្តិទាំងពីរនេះ មិនមានការដាក់កម្រិតភាសា ឬមិនមានចែងពីការលើកលែងណាមួយចំពោះវិធានទូទៅដែលបានលើកឡើងឡើយ ។ ហើយការលើកលែងបែបនេះ ក៏មិនអាចរកឃើញនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ឬវិធានផ្ទៃក្នុងបានដែរ ។ ជាសរុបបញ្ហា

---

[4] សូមមើលសេចក្ដីសន្និដ្ឋានសាក្សី នៅកថាខណ្ឌទី ១២-២៩ ។

[5] កំណត់សំគាល់: ការទទួលស្គាល់សេចក្ដីត្រូវការដើម្បីធានាថា ដំណើការនីតិវិធីរបស់ អវតក គោរពតាមបទដ្ឋានច្បាប់ដែលត្រូវបានបង្កើតឡើងនៅទូទាំងសកលលោក, ដូច្នេះច្បាប់ស្ដីពីការបង្កើត អវតក និងកិច្ចព្រមព្រៀងអនុញ្ញាតឲ្យអនុម័តវិធាននីតិវិធីបន្ថែមនៅក្នុងទិដ្ឋភាពបី ជាពិសេសនៅពេល (i) ដែលច្បាប់ និងនីតិវិធីដែលមានស្រាប់ "ពុំមានចែងពីករណីពិសេសមួយ (ii) មានភាពមិន ច្បាស់លាស់ក្នុងការបកស្រាយ ឬ អនុវត្តនីតិវិធីនោះ ឬ (iii) នៅមានបញ្ហាទាក់ទងនឹងភាពសមស្របនៃនីតិវិធីទាំងនេះជាមួយបទដ្ឋាន អន្តរជាតិ" ។ កិច្ចព្រមព្រៀង អវតក, មាត្រា ១២(១), ច្បាប់, មាត្រា ២០ថ្មី, ២៣ថ្មី ។ សូមមើលផងដែរករណី 00១, ឯកសារ E-188 សេចក្ដីសម្រេចជាធារណៈ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ERN 00572517–00572797 ("សាលក្រម ឌុច") នៅកថាខណ្ឌទី៣៥ ។ នៅក្នុងករណីបែបនេះ- និងមានតែករណីបែបនេះ- "ការណែនាំ" អាចត្រូវស្វែងរក "ក្នុងបទដ្ឋានីតិវិធីដែលបានបង្កើតឡើងនៅ កម្រិតអន្តរជាតិ" ។ *ដូចខាងលើ ។* ការទទួលស្គាល់នីតិវិធីថ្មី ឬការងាកចេញណាមួយពីនីតិវិធីដែលមានស្រាប់ និងនៅជាធរមាន" ហេតុដូច្នេះ ត្រូវតែបានធ្វើយុត្តិកម្មដោយយោងចំពោះករណីលើកលែងដែលកំណត់ដោយច្បាប់ ។ វិធីសាស្ត្រណាមួយដទៃទៀត ឧទាហរណ៍ ការបង្កើតវិធានថ្មីដើម្បីឲ្យមានប្រសិទ្ធិភាពកាន់តែច្រើនថែមទៀត គឺការរំលោភដោយផ្ទាល់នៃនិយមន័យនៃ មាត្រា ១២(១) នៃកិច្ចព្រមព្រៀង អវតក ។ សូមមើលឯកសារ E-51/3 អញ្ញត្រកម្មរួមគ្នា" ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១១ ERN 00648279–00648310 នៅកថាខណ្ឌទី៦៦-៧២ ។

នៃសក្ខីកម្មនៃបដិសាក្សី គឺមានចែងយ៉ាងច្បាស់លាស់ យ៉ាងខ្លី និងពេញលេញនៅក្នុងច្បាប់កម្ពុជាដែលនៅជាធរមាន ។ និយាយឲ្យសាមញ្ញទៅ បដិសាក្សីទាំងអស់ដែលមិនទាន់តទល់ជាមួយជនជាប់ចោទព្រមជាមួយសក្ខីកម្មរបស់អ្នកដែលអង្គជំនុំជម្រះមានបំណងយកមកប្រើក្នុងការធ្វើសេចក្ដីសម្រេចប្រឆាំងនឹង នួន ជា ត្រូវតែចូលខ្លួនក្នុងតុលាការ និងផ្ដល់សក្ខីកម្មដោយផ្ទាល់មាត់ ។

## ខ. ពុំមានភាពមិនច្បាស់លាស់ទាក់ទងនឹងការបកស្រាយ ឬ ការអនុវត្តមាត្រា ២៩៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឬ វិធាន ៨៤(១) នៃវិធានផ្ទៃក្នុងឡើយ

៤. តាមវាក្យសព្ទយ៉ាងច្បាស់លាស់របស់វា វិធានដែលបានលើកឡើងខាងលើ គឺជាវិធានដាច់ខាតមួយ ។ អង្គជំនុំជម្រះមិនអាចទទួលយកកំណត់ហេតុនៃការស្ដាប់ចម្លើយរបស់បដិសាក្សីជំនួសឲ្យសក្ខីកម្មផ្ទាល់មាត់របស់ពួកគេបាន ប្រសិនបើសាក្សីទាំងនេះមិនត្រូវបានកោះហៅឲ្យចូលខ្លួនក្នុងសវនាការជាចំហ ហើយក៏មិនមានចំណុចចន្លោះប្រហោងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ឬវិធានផ្ទៃក្នុងទាក់ទងនឹងការសួរចម្លើយបដិសាក្សី ត្រូវប្រាស់ប្រើនីតិវិធីខាងក្រៅដែរ។ បើជាយ៉ាងណាក៏ដោយ ក៏ កសព បាន ប៉ុនប៉ងបង្កើតការភ័ន្តច្រឡំ ក្នុងករណីដែលពុំមានការភ័ន្តច្រឡំនេះកើតឡើងនោះ៖

- ក. ការណ៍ដែលថាមានតែអត្ថបទភាសាអង់គ្លេសនៃវិធាន៨៤(១)ទេនិយាយយោងពីសិទ្ធិដាច់ខាតនេះ តែវាក៏មិនបានដល់កម្រិតនៃភាពមិនច្បាស់លាស់ដែរ[6]។ នៅពេលអានស្របគ្នានឹងមាត្រា ២៩៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា (ដែលត្រូវធ្វើយ៉ាងដូច្នេះ) ការធានាដែលមានចែងនៅក្នុងវិធាន៨៤(១) មិនអាចត្រូវបានគេយល់ថាជាអ្វីផ្សេងទេតែមិនគ្រប់លក្ខណៈសម្បត្តិ ។ តាមពិតប្រយោគភាសាខ្មែរដែលមានលក្ខណៈបង្គាប់ *"ត្រូវតែកោះហៅ"* សន្និដ្ឋានអ្វីមួយដែលមានលក្ខណៈច្រើនជាងសិទ្ធិរបស់ជនជាប់ចោទក្នុងការស្នើសុំការតទល់ជាមួយបដិសាក្សីទៅទៀត ។ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាថែមទាំងដាក់ករណីកិច្ចជាអវិជ្ជមានដល់អង្គជំនុំជម្រះហៅបុគ្គលទាំងនោះ បើសិនជា

---

[6] សូមមើលសេចក្ដីសន្និដ្ឋានសាក្សី នៅកថាខណ្ឌទី ៣-៤ ។

អង្គជំនុំជម្រះមានបំណងប្រើប្រាស់សក្ខីកម្មរបស់ពួកគេ ។ ការណ៍ដែលថាការលើកលែងមិនត្រូវបានចែងឲ្យបានជាក់លាក់ នោះវាគាំទ្រដល់ជំហរនេះ[7]។

ខ. អត្ថន័យនៃប្រយោគ "ប្រឆាំងនឹងគាត់" មិនសូវច្បាស់[8] ។ វាពន្លាតជំនឿទុកចិត្តដើម្បីធ្វើការសន្និដ្ឋានថាអត្ថន័យរបស់ភាសាដែលមានន័យត្រង់នេះ គឺគ្មានអ្វីក្រៅតែពីភាពច្បាស់លាស់នេះឯង ។ អាយតនិបាតភាសាអង់គ្លេស *ប្រឆាំងនឹង (against)* ត្រូវបានកំណត់និយមន័យដោយសាមញ្ញថា: "ប្រឆាំងនឹង (in opposition to), ផ្ទុយនឹង (contrary to), ប្រឆាំង ឬ ប្រទូសរ៉ាយ"[9] (adverse or hostile to)។ បើតាមទស្សនៈរបស់ Guido Acquaviva[10] បុគ្គលណាម្នាក់ដែលសក្ខីកម្មរបស់ខ្លួនអាចបង្ហាញដល់

---

[7] កំណត់សំគាល់: ការណ៍ដែលថាបើមានមន្ទិលសង្ស័យលេចឡើងទាក់ទងនឹងការបកស្រាយច្បាប់នីតិវិធីកម្ពុជាដែលនៅជាធរមានភាពមិនប្រក្រតីនេះត្រូវតែបានដោះស្រាយជាប្រយោជន៍ដល់ នួន ជា ស្របតាមគោលការណ៍ទូទៅ *favor rei* (ដែលគ្រប់ដណ្តប់គោលការណ៍ជាក់លាក់ភស្តុតាងជាក់លាក់នៃវិមតិសង្ស័យ) ។ សូមមើល A. Casese (ED) ការប្រៀបធៀបយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ (Oxford 2009) នៅទំព័រ ៤៤០-៤៤៤ (*favor rei* គឺជាគោលការណ៍ [...] តម្រូវ នៅក្នុងករណីមានទំនាស់ក្នុងការបកប្រែវិធានរដ្ឋធម្មនុញ្ញជាប្រយោជន៍ដល់ជនជាប់ចោទ ។ [...] ក៏ត្រូវបានគេយល់ថាជាបទដ្ឋានសម្រាប់គ្រប់គ្រងភស្តុតាង: នៅក្នុងករណីនេះ គោលការណ៍នេះ ត្រូវបានគេស្គាល់ថាជាវិមតិសង្ស័យ") ("សំអាងយុត្តិសាស្ត្រអន្តរជាតិ) ។ គោលការណ៍នេះមានចែងនៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជា ។ សូមមើលមាត្រា ៣៨ នៃ រដ្ឋ ធម្មនុញ្ញ "វិមតិសង្ស័យ [...] ត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ")។ ដូចគ្នាដែរ វិធានផ្ទៃក្នុង "ត្រូវតែបកស្រាយក្នុងន័យការពារ ជានិច្ចដល់ផលប្រយោជន៍របស់ជនត្រូវចោទ និងជនជាប់ចោទ" ។ ("បញ្ជាក់បន្ថែម")។ វិធាន ២១(១) ។ សូមមើលផងដែរសាលក្រម ឌុច "មតិដាច់ដោយ ឡែក និងមតិជំទាស់របស់ចៅក្រម Jean-Marc Lavergne ទាក់ទងនឹងការផ្តន្ទាទោស ("មតិជំទាស់ចៅក្រម Lavergne ) នៅកថា ខណ្ឌទី៨ (ចែងថា "នៅពេលដែលច្បាប់នេះមិនមានភាពច្បាស់លាស់ ឬមិនមានចែង ពេលនោះគេត្រូវប្រកាន់យក នូវដំណោះ ស្រាយ ដែលផ្តល់ជាប្រយោជន៍ដល់ជនជាប់ចោទ នៅពេលមានភាពមិនច្បាស់លាស់ក្នុងការអនុវត្តវិធានជាក់លាក់ណាមួយនោះ" ។ សូមកត់ សំគាល់ថា "គោលការណ៍ដែលត្រូវគេទទួលស្គាល់យ៉ាងទូលំទូលាយ វិមតិសង្ស័យត្រូវតែបានដោះស្រាយជាប្រយោជន៍ដល់ជនជាប់ ចោទ" ហើយការយោងយុត្តិ សាស្ត្រអន្តរជាតិសម្រាប់សំណើខាងក្រោម: "គោលការណ៍ដែលថាវិមតិសង្ស័យត្រូវតែបានដោះ ស្រាយ ជាប្រយោជន៍ដល់ ជនជាប់ចោទមិនអនុវត្តចំពោះតែការវាយតម្លៃភស្តុតាងពាក់ព័ន្ធទៅនឹងពិរុទ្ធភាពរបស់ជនជាប់ចោទប៉ុណ្ណោះទេ តែ ការអនុវត្តរបស់វាមានលក្ខណៈទូលំទូលាយ និងរួមបញ្ចូលទាំងការបកស្រាយបទដ្ឋានច្បាប់ដែលនៅជាធរមានដែលមិនច្បាស់លាស់ ទៀតផង" ។

[8] សូមមើលសេចក្តីសន្និដ្ឋានសាក្សី នៅកថាខណ្ឌទី៤ ។

[9] Dictionary.com (unabridged), based on the Random House Dictionary (Random House 2011).

[10] សូមមើលសេចក្តីសន្និដ្ឋានសាក្សី អក្សរក្នុងលេខយោងទី៨ ។

ទិដ្ឋភាពនៃការចោទប្រកាន់របស់ព្រះរាជអាជ្ញា នឹងធ្លាក់ចូលក្នុងរង្វង់នៃនិយមន័យទូលំទូលាយ[11] ហើយដូច្នេះ ត្រូវតែបានចាត់ទុកថាជាសាក្សីប្រឆាំងនឹងជនជាប់ចោទ ។ ការបែកជាចំពាមដែលស្នើឡើងដោយ កសព "អំពើ និងការប្រព្រឹត្តរបស់ជនជាប់ចោទ ដែលផ្ទុយទៅនឹងភស្តុតាងគាំទ្រ ដែលដល់ការចោទប្រកាន់មានលក្ខណៈទូលំទូលាយជាង"[12] មិនមានគុណសម្បត្តិនៅក្នុងប្រព័ន្ធច្បាប់កម្ពុជាដែលនីតិវិធីទាក់ទងនឹងសក្ខីកម្មពីបដិសាក្សី ពុំបានចែងពីភាពខុសគ្នានេះទេ ។ បន្ថែមពីលើការធ្វើឲ្យនឹកឃើញដល់ការសំឡឹងមើលវចនានុក្រម "ការណែនាំបន្ថែមសម្រាប់ឲ្យចៅក្រមយល់ពីគោលបំណងនៃពិរុទ្ធភាព គឺមិនត្រូវការឡើយ[13]។ សក្ខីកម្មបែបនេះនឹងរួមបញ្ចូល "អំពើ និងការប្រព្រឹត្តរបស់ជនជាប់ចោទ ដូចដែលបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ", "អំពើ និងការប្រព្រឹត្តរបស់អ្នកនៅក្រោមបង្គាប់ផ្ទាល់របស់ជនជាប់ចោទ", "ជាបញ្ហាសំខាន់នៅក្នុងករណីនេះ" និងអ្វីផ្សេងទៀត ដែលមានបំណងដាក់កំហុសមកលើជនជាប់ចោទ ដែលអាចមានន័យជាក់លាក់ ឬទូលំទូលាយ ។

គ. ពុំមាន "ភាពមិនស្របគ្នា" រវាងការគោរពសិទ្ធិរបស់ជនជាប់ចោទ និង"គោលការណ៍ជាមូលដ្ឋាន" ដែលមានចែងនៅក្នុងវិធាន ២១ ឡើយ"[14]។ តាមពិតគោលបំណងដ៏ចម្បងមួយក្នុងចំណោមគោលបំណងជាច្រើនទៀតរបស់វិធាននោះ គឺថាវិធាននេះត្រូវ "ការពារផលប្រយោជន៍របស់ជនជាប់ចោទ"[15]។ វាមិនច្បាស់លាស់ទាល់តែសោះថា តើការគោរពសិទ្ធិដាច់ខាតរបស់ នួន ជា ក្នុងការតទល់ជាមួយបដិសាក្សី នឹងរំខានដល់

[11] កំណត់សំគាល់: បើសិនជាគ្មានអង្គហេតុដែលគ្មានជំទាស់ទេ- ដូចជានៅក្នុងករណីនេះ- "ករណីព្រះរាជអាជ្ញា" បើតាមនិយមន័យរបស់វា គឺជាការប្រឆាំង, ផ្ទុយនឹង, ប្រឆាំងទៅនឹង និង អមិត្តទៅនឹងជំហររបស់ជនជាប់ចោទ។

[12] សូមមើលសេចក្តីសន្និដ្ឋានសាក្សី នៅកថាខណ្ឌទី៤ ។

[13] ដូចខាងលើ ។

[14] សូមមើលសេចក្តីសន្និដ្ឋានសាក្សី នៅកថាខណ្ឌទី៤ ។

[15] វិធាន ២១(១) ។

“តុល្យភាពរវាងសិទ្ធិរបស់ភាគីនានា”ដែរ ឬអត់នោះ[16] ។ អ្វីដែល កសព កំពុងតែព្យាយាមបង្ហាញនៅទីនេះ គឺការខកចិត្តរបស់គាត់ជាមួយនឹងទំហំ និងវិសាលភាពនៃករណីនេះ និងតម្រូវការពេលវេលាដ៏ច្រើនដើម្បីបង្ហាញករណីនេះ(ឲ្យបានត្រឹមត្រូវ) ហួសពីវិមតិសង្ស័យ ហើយការពិចារណាបែបនេះ មិនសក្តិសមឡើយ ។ ពេលវេលាសម្រាប់ពិភាក្សាបានកន្លងផុតទៅហើយ ។ បើសិនការពន្លឿននីតិវិធីនៃការជំនុំជម្រះពិតជាការព្រួយបារម្ភណ៍មួយក្នុងចំណោមកាព្រួយបារម្ភណ៍នានារបស់ កសព ចាប់តាំងពីការចាប់ផ្តើមនៃករណីនេះមែន នោះគេនឹងអាចរំពឹងទុកថាការថប់បារម្ភនេះត្រូវតែបង្ហាញនៅក្នុងសេចក្តីសន្និដ្ឋានបញ្ជូនឲ្យស៊ើបសួរដែលអាចគ្រប់គ្រងបាន ។ តែឯកសារដែលមានទំហំដ៏ធំ និងលំអិតពិតជាបានដាក់ជូនឆ្នាំកន្លងមក បានផ្ទុះបញ្ចាំងដោយដីកាបញ្ជូនរឿងទៅជំនុំជម្រះយ៉ាងវែងរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត(“កសចស”) ។ (យ៉ាងហោចណាស់ក៏អាចនិយាយថា) វាមិនស្មោះត្រង់ទេក្នុងការលើកឡើងថាសិទ្ធិរបស់ នួន ជា ក្នុងការតទល់ជាមួយសាក្សីប្រឆាំងនឹងគាត់ត្រូវតែពង្រួញមកឲ្យខ្លី ដោយសារការអនុវត្តឲ្យមានប្រសិទ្ធិភាពនៃការធានាដ៏ពិសិទ្ធិនេះ ប្រើពេលវេលាយូរអង្វែងពេក ។ ដូច Victor Frankenstein នៅមុនពួកគេ សហព្រះរាជអាជ្ញាមិនអាចបញ្ចៀសផលពិបាកដែលបង្កើតឡើងដោយខ្លួនឯងបានឡើយ ។

ឃ. ការណ៍ដែលថាប្រព័ន្ធនីតិវិធីរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិមួយចំនួន មានវិធានជាក់លាក់ទាក់ទិននឹងការទទួលយកកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មិនបង្កើតភាពចន្លោះប្រហោងនៅក្នុងនីតិវិធីនៅចំពោះ អវតក[17] ។ បើតាមការលើកឡើងរបស់ កសព ក្នុងករណីដែលវិធាន ICTY (ឧទាហរណ៍) មានចែងពីបញ្ហាជាក់លាក់ជាងបទបញ្ញត្តិនីតិវិធីស្រដៀងរបស់កម្ពុជា ដូច្នេះច្បាប់នីតិវិធីកម្ពុជាត្រូវចាត់ទុកថាមានចន្លោះប្រហោងដែលត្រូវបំពេញដោយច្បាប់នីតិវិធីអន្តរជាតិ។ “ការបំពេញចន្លោះ

[16] សូមមើលសេចក្តីសន្និដ្ឋានសាក្សី នៅកថាខណ្ឌទី៤ ។

[17] ដូចខាងលើ នៅកថាខណ្ឌទី៥ ។

ប្រហោង"ច្រើនពេក -ពិតជាមិនមែនដំណើរការដែលរំពឹងទុកដោយអ្នកពង្រាងកិច្ចព្រមព្រៀង និងច្បាប់បង្កើត អវតក ឡើយ- នឹងច្រានចោលបទបញ្ញត្តិដ៏ល្អឥតខ្ចោះរបស់កម្ពុជា ដោយមូលហេតុថាច្បាប់កម្ពុជាខ្វះភាពទាន់សម័យដូចច្បាប់អន្តរជាតិ។ ទន្ទឹមគ្នានេះដែរច្បាប់កម្ពុជាពុំមានបទបញ្ញត្តិ*ជាក់លាក់* ទាក់ទងនឹងការទទួលយកកំណត់ហេតុជាលាយអក្ខណ៍នៃការស្តាប់ចម្លើយសាក្សី ឬ ប្រតិចារិតពីការជំនុំជម្រះក្តីដទៃទៀត[18] ដូច្នេះ"គោលការណ៍ទូទៅដែលអនុវត្តចំពោះការទទួលយកភស្តុតាង"[19] ដែលមានចែងនៅក្នុងមាត្រា ៨៧(១) និងមាត្រា ៣២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា គឺមានលក្ខណៈបត់បែនគ្រប់គ្រាន់ដើម្បីដោះស្រាយបញ្ហានេះបាន[20]។ ទាក់ទងនឹងចំណុចនេះអ្វីដែលជាជំហររបស់ កសព គឺថាច្បាប់កម្ពុជាមានបទបញ្ញត្តិជាក់លាក់ និងច្បាស់លាស់ទាក់ទងនឹងការយកសក្ខីកម្មរបស់បដិសាក្សី ជាពិសេសមាត្រា ២៩៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងវិធាន ៨៤(១) នៃវិធានផ្ទៃក្នុង ។

ង. ជាទីបញ្ចប់ "ទំនាក់ទំនងរវាងវិធាន ៨៧(១) និង វិធាន ៨៤(១)"[21] គឺច្បាស់លាស់ ។ វិធាន៨៧(១) គឺជាវិធានទូទៅទាក់ទងនឹងការទទួលយកភស្តុតាង ហើយវិធាន៨៤(១) គឺជាវិធានពិសេសទាក់ទងនឹងសក្ខីកម្មរបស់បដិសាក្សី។ អនុលោមតាមវិធាន ៨៧(១) លើកលែងតែមានបទបញ្ញត្តិផ្សេង [...] រាល់ភស្តុតាងទាំងអស់ត្រូវតែទទួលយក" ។ វិធាន៨៤(១) និងមាត្រា២៩៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាចែងផ្សេង (ក្នុងកម្រិតមួយ) តម្រូវឱ្យបដិសាក្សីដែលមានទាំងអស់ ត្រូវតែបានស្តាប់សក្ខីកម្មដោយផ្ទាល់មាត់នៅចំពោះមុខអង្គជំនុំជម្រះ ដូចដែលតម្រូវដោយលក្ខខណ្ឌនៃភាពអាចទទួលយកនៃភស្តុតាង។

---

[18] ដូចខាងលើ ។

[19] ដូចខាងលើ ។

[20] កំណត់សំគាល់៖ តាមពិតអង្គជំនុំជម្រះបានបង្ហាញចំណុចនេះរួចមកហើយ ព្រមទាំងការយោងទៅលើគោលការណ៍អន្តរ ជាតិនៅពេលចាំបាច់ តាមករណីជាក់ស្តែង ។ សូមមើលអក្សរក្នុងយោងលេខ ២៨ ខាងក្រោម ៕

[21] ដូចខាងលើ នៅកថាខណ្ឌទី៥ ។

៥. សរុបមក សហព្រះរាជអាជ្ញាបានជ្រើសរើសយកគោលការណ៍ដែលមានលក្ខណៈមិនច្បាស់លាស់ជាទីបំផុតទាក់ទងនឹងច្បាប់កម្ពុជា (ដែលបានបញ្ជាក់យ៉ាងច្បាស់ និងទូលំទូលាយក្នុងមាត្រា ២៩៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា និងមាត្រា៨៤(១) និងបានព្យាយាមធ្វើឱ្យច្របូក ច្របល់នូវខ្លឹមសារដែលមិនច្បាស់លាស់របស់វាឱ្យហួសពីការទទួលស្គាល់ទៅទៀត ។ ការខ្វះភាពច្បាស់លាស់ទាក់ទងនឹងភាពអាចទទួលយកបាននៃកំណត់ហេតុជាលាយលក្ខអក្សរនៃចម្លើយមួយចំនួនរបស់សាក្សី[22] មិនបានផ្លាស់ប្តូរលក្ខខណ្ឌតម្រូវច្បាស់លាស់ដែលថាបដិសាក្សីដែលអាចរកបានទាំងអស់ដែលពីមុនមក មិនត្រូវបានតទល់ដោយជនជាប់ចោទ ត្រូវតែផ្តល់សាក្សីកម្មដោយផ្ទាល់មាត់នៅចំពោះមុខអង្គជំនុំជម្រះនេះ ។

### *៣. វាមិនមានបញ្ហាទាក់ទងនឹងភាពស្របគ្នារវាងច្បាប់កម្ពុជា និងបទដ្ឋានអន្តរជាតិ*

៦. មាត្រា ២៩៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា និងមាត្រា៨៤(១) គឺសមស្របជាមួយបទដ្ឋានអន្តរជាតិដែលបានបង្កើតឡើង ។ តាមពិតដំណោះស្រាយរបស់កម្ពុជាចំពោះសាក្សីកម្មរបស់ បដិសាក្សីដែលផ្តល់សិទ្ធិមិនស្មើភាពគ្នា ដើម្បីតទល់បដិសាក្សីទាំងអស់នៅសវនាការ(ឧបមាថាជនជាប់ចោទកាលពីមុនមិនមានឱកាសធ្វើដូច្នេះ) គឺហួសឆ្ងាយពីវិធានការណ៍ការពារជាអប្បបរមាដែលបានផ្តល់ឱ្យដោយច្បាប់សិទ្ធិមនុស្សអន្តរជាតិ[23]។

៧. កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិនយោបាយ និងសិទ្ធិពលរដ្ឋ (ICCPR) (ដែលអាចអនុវត្តបានចំពោះដំណើរការនីតិវិធីទាំងនេះតាមអំណាចរបស់ធម្មនុញ្ញបច្ចុប្បន្ននៃកម្ពុជា[24]) ការពារដល់ភាពដែលមិនអាចរំលោភបាននៃច្បាប់ណាមួយ ដែលផ្តល់ការការពារកម្រិតខ្ពស់ជាងនេះដល់សិទ្ធិនយោបាយ និងសិទ្ធិពលរដ្ឋ ជាងសិទ្ធិដែលមានចែងក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិនយោបាយ និងសិទ្ធិពលរដ្ឋ[25]។

---

[22] សូមមើលកថាខណ្ឌទី៩, ខាងលើ។

[23] សេចក្តីសន្និដ្ឋានសាក្សី, កថាខណ្ឌទី៧ ដល់១១ ។

[24] សូមមើលរដ្ឋធម្មនុញ្ញកម្ពុជានៅមាត្រា៣១ (ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីសម្រេចជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាទាំងឡាយទាក់ទងនឹងសិទ្ធិមនុស្ស[...])។

[25] ឯកសារ **D-427/1/6**, “បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ” ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១០ 00617486–00617631, នៅអក្សរក្នុងលេខយោងទី២១០ (លើកមកសំអាងរឿងក្តី Manfred Novak, កតិកាសញ្ញា ICCPR:

ដូច្នេះ ក្នុងបរិបទនៃវិវាទព្រហ្មទណ្ឌអន្តរជាតិក្នុងប្រព័ន្ធច្បាប់ជាតិ សញ្ញាណនៃបទដ្ឋានអន្តរជាតិត្រូវតែបានគេយល់ថាជាការផ្តល់ការធានាជាមូលដ្ឋានដល់ការជំនុំជម្រះក្តីដោយយុត្តិធម៌ ដែលយុត្តាធិការជាតិអាចងាកចេញដោយសេរីដើម្បីគាំទ្រដល់ការធានាដ៏ត្រឹមត្រូវ និងតឹងរឹងជាងមុន ពោលគឺ*ការការពារច្រើនជាងមុន* ។ ទោះជាក្នុងករណីណាក៏ដោយ តាមពិតទៅវានឹងក្លាយជាតក្កវិជ្ជារឹងទទឹងរកផ្លូវខុស (និងជាការរំលោភដល់អធិបតេយ្យភាពរបស់កម្ពុជា) ដែលលើកឡើងថាច្បាប់ជាតិត្រូវបានរាំងមិនឱ្យអនុម័តច្បាប់និងនីតិវិធី*ដែលហួសពី*លក្ខខណ្ឌវិនិច្ឆ័យជាអប្បបរមាដែលផ្តល់ឱ្យដោយច្បាប់អន្តរជាតិ

៨. ដូច្នេះ បើពិនិត្យទៅលើបទដ្ឋានខ្ពស់ដែលចែងដោយនីតិវិធីកម្ពុជាដែលមានស្រាប់ ការសំអាងរបស់សហព្រះរាជអាជ្ញាទៅលើវិធីសាស្ត្រដែលមានការការពារតិច ដែលអនុម័តដោយតុលាការអឺរ៉ុបសិទ្ធិមនុស្ស និងតុលាការព្រហ្មទណ្ឌអន្តរជាតិដទៃទៀត គឺមិនសក្តិសមឡើយ[26]។ ជាថ្មីម្តងទៀតនៅ អវតក ក៏ដូចជាតុលាការក្នុងស្រុករបស់ប្រទេសកម្ពុជាផងដែរ នៅករណីដែលបដិសាក្សី (ដែលត្រូវបានឱ្យនិយមន័យយ៉ាងលំទូលាយដូចដែលបានពិភាក្សាខាងលើ[27]) ដែលពីមុនមិនត្រូវបានសួរចម្លើយតទល់អាចផ្តល់សក្សីកម្មបាន ហើយដូច្នេះ សក្សីកម្មរបស់សាក្សីនោះត្រូវតែធ្វើឡើងដោយផ្ទាល់មាត់នៅក្នុងសវនាការ ដើម្បីឱ្យអង្គជំនុំជម្រះពិចារណាលើសក្សីកម្មរបស់គាត់ "ប្រឆាំង" នឹងជនជាប់ចោទ ។ គេអាចនិយាយពីយុត្តិសាស្ត្រអន្តរជាតិ តែគេមិនអាច (ឬគួរ) ផ្លាស់ប្តូរគោលជំហរច្បាប់ក្នុងស្រុកដែលបានបង្កើតឡើងបានឡើយ ។

## ខ. ការទទួលយកកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់សាក្សីជំនួសឱ្យសក្សីកម្មផ្ទាល់មាត់អាចទទួលយកបានក្នុងករណីមួយចំនួនដោយមានលក្ខខណ្ឌ

---

បទអត្ថាធិប្បាយលេខ ១១៨ ((NP Engel 2005)) ។ សូមមើលមាត្រា ៥(២) ICCPR "មិនត្រូវធ្វើវិតត្បិត ឬធ្វើបដិប្បញ្ញត្តិណាមួយឡើយទៅលើសិទ្ធិជាមូលដ្ឋានរបស់មនុស្ស ដែលត្រូវបានទទួលស្គាល់ ឬដែលនៅជាធរមានក្នុងរដ្ឋភាគីនៃអនុសញ្ញានេះ ដោយអនុលោមតាមច្បាប់ អនុសញ្ញា បទបញ្ញា ឬទំនៀមទំលាប់ ដោយលេសថាកតិកាសញ្ញានេះមិនទទួលស្គាល់សិទ្ធិទាំងនោះ ឬទទួលស្គាល់សិទ្ធិទាំងនោះក្នុងកម្រិតទាបជាង ។ (បញ្ជាក់បន្ថែម)

[26] សេចក្តីសន្និដ្ឋានសាក្សី, កថាខណ្ឌទី៧ ដល់២៩ ។

[27] សូមមើលកថាខណ្ឌទី៤(ខ) ខាងលើ ។

៩. មេធាវីការពារក្តីទទួលស្គាល់ថានីតិវិធីកម្ពុជាដែលមានស្រាប់ មិនបានលើកឡើងឲ្យបានច្បាស់លាស់អំពីការទទួលយកកំណត់ហេតុនៃការស្តាប់ចម្លើយរបស់បដិសាក្សី ក្នុងស្ថានភាពមួយដែលអ្នកផ្តល់សក្ខីកម្ម មិនអាចផ្តល់សក្ខីកម្មដោយផ្ទាល់មាត់ក្នុងតុលាការបាន (*stricto sensu*) ក្នុងបរិបទនេះ សហព្រះរាជអាជ្ញាបានបង្ហាញគោលការណ៍អន្តរជាតិត្រឹមត្រូវមួយដែលអង្គជំនុំជម្រះគួរតែពិនិត្យប្រសិនបើ និងនៅពេលដែលអង្គជំនុំជម្រះចាំបាច់ពិចារណាសេណារីយ៉ូបែបនេះ ។ ដូចដែលបានកត់សម្គាល់ដោយសហព្រះរាជអាជ្ញា អង្គជំនុំជម្រះបានធ្វើដូច្នេះរួចមកហើយកាលពីមុននៅក្នុងសំណុំរឿង ០០១[28] ។

១០. ក្នុងការសម្រេចថាតើបដិសាក្សីជាក់លាក់ណាមួយពិតជាមិនអាចរកបាន ដើម្បីផ្តល់សក្ខីកម្មដោយផ្ទាល់មាត់ដែរឬអត់នោះ និងដើម្បីពិនិត្យអំណះអំណាងផ្ទុយ អង្គជំនុំជម្រះគួរតែអនុវត្តការវាយតម្លៃឲ្យបានតឹងរឹងឲ្យស្របទៅតាមគោលបំណងរបស់វិធាន៨៤(១) និងមាត្រា២៩៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាដែលតម្រូវឲ្យផ្តល់ភស្តុតាងនៅសវនាការជាសាធារណៈដោយមានវត្តមានជនជាប់ចោទ[29]។ ជាពិសេសបដិសាក្សីត្រូវបានគេចាត់ទុកថាមិនអាចរកបាន ប្រសិនបើគាត់បានទទួលមរណៈភាព ឬមិនអាចផ្តល់សក្ខីកម្មបានដោយសារអសមត្ថភាពខាងរូបរាងកាយឬស្មារតី ឬត្រូវបានការពារដោយអភ័យ

[28] សូមមើលសំណុំរឿង ០០១, ឯកសារសាធារណៈ **E-43/4** "សេចក្តីសម្រេចលើភាពអាចទទួលយកបាននៃសម្ភារៈនៅក្នុងសំណុំរឿងជាភស្តុតាង" ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៩ ERN [...], [...] ("សេចក្តីសម្រេចលើភាពអាចទទួលយកបាននៃភស្តុតាង") នៅកថាខណ្ឌទី១៥ ("នៅពេលដែលភស្តុតាងអាចបញ្ជាក់ពីអំពើ និងការប្រព្រឹត្តរបស់ជនជាប់ចោទ ដូចដែលបានចោទប្រកាន់មែន, នេះគឺជាកត្តា ប្រឆាំងនឹងភាពអាចទទួលយកបាននៃភស្តុតាង ឬផ្នែករបស់វា") (លើកមកសំអាងនៃសេចក្តីសម្រេចនៅក្នុងករណី Charles Taylor) កត់សំគាល: នៅក្នុងករណី ឌុច កំណត់ហេតុស្តាប់ចម្លើយរបស់មរណៈជន ដែល ឌុច មិនមានឱកាសតទល់ និងកំណត់ហេតុនៃការ ស្តាប់ចម្លើយរបស់អ្នកដែលនិយាយពីការប្រព្រឹត្តអំពើព្រហ្មទណ្ឌរបស់ជាប់ចោទ ត្រូវបានបដិសេធដោយអង្គជំនុំជម្រះ អនុលោមតាម វិធាន ៨៧(៣) ។ ដូចខាងលើ នៅកថាខណ្ឌទី១៦ ។ ខណៈដែលអង្គជំនុំជម្រះទទួលស្គាល់ពី "ការលើកលែងចំពោះគោលការណ៍ ទូទៅ" អង្គជំនុំជម្រះយល់ឃើញថា "ខណៈជាគោលការណ៍ទូទៅ ជនជាប់ចោទទទួលបានឱកាសគ្រប់គ្រាន់ដើម្បីជំទាស់ និងសួរចម្លើយសាក្សីប្រឆាំងនឹងគាត់ ។ ដូចខាងលើនៅកថាខណ្ឌទី ១៤ (សំអាងលើយុត្តិសាស្ត្ររបស់ ECtHR) ។ គោលការណ៍ទូទៅ មានចែងដូចខាងក្រោម: "ជាផ្នែករបស់សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដែលជាធម្មតាត្រូវបានគេសន្មតថាភស្តុតាងត្រូវបានបង្កើតឡើងនៅសវនាការសាធារណៈ នៅចំពោះមុខវត្តមានរបស់ជនជាប់ចោទ" ។ ដូចខាងលើ ។

[29] សេចក្តីសម្រេចលើភាពអាចទទួលយកបាននៃសម្ភារៈ នៅកថាខណ្ឌទី១៤ ។

ឯកសិទ្ធិផ្លូវច្បាប់ដែលត្រូវបានទទួលស្គាល់ ។ បដិសាក្សីដែលគ្រាន់តែបដិសេធមិនព្រមចូលខ្លួននៅចំពោះមុខតុលាការ មិនត្រូវចាត់ទុកថាមិនអាចរកបានឡើយ បើមិនដូច្នេះទេ ការជម្រុញផ្នែកនយោបាយ (ឬការជម្រុញដែលមិនទាក់ទងនឹងវិស័យតុលាការដទៃទៀត) ទៅលើផ្នែកនៃសាក្សីម្នាក់ៗ ឬកម្លាំងធំជាងនេះដែលគ្រប់គ្រងពួកគេ អាចត្រូវបានប្រើប្រាស់ដើម្បីទប់ស្កាត់សាក្សីទាំងនោះមិនឱ្យផ្ដល់សក្ខីកម្មផ្ទាត់មាត់ដ៏សំខាន់ ។ អង្គជំនុំជម្រះគួរតែប្រើគ្រប់វិធានការដែលមានទាំងអស់[30] ដើម្បីធានាឱ្យមានការចូលរួមនៅសវនាការរបស់បដិសាក្សីដែលអាចរកបានទាំងអស់ ។

១១. នៅពេលវាត្រូវបានសម្រេចតាមផ្លូវតុលាការថាបដិសាក្សីពិតជាមិនអាចរកបានមែន នោះអង្គជំនុំជម្រះគួរតែងាកទៅរកការចោទសួរពីទំហំ ដែលអាចទទួលយកបាននៃសក្ខីកម្មជាលាយលក្ខណ៍អក្សរដែលមិនត្រូវបានជំទាស់របស់សាក្សីនោះ។ ជាថ្មីម្តងទៀតសហព្រះរាជអាជ្ញាបានកំណត់កត្តាពាក់ព័ន្ធជាច្រើន (ដែលមិនទាន់អស់) ដើម្បីពិចារណាថា តើសក្ខីកម្មនេះទាក់ទងនឹងអំពើ និងការប្រព្រឹត្តរបស់ជនជាប់ចោទដែរ ឬទេ, កម្រិតនៃចរិតលក្ខណៈនៃការជាប់ពាក់ព័ន្ធរបស់ភស្តុតាង ដែលផ្ទុយទៅនឹងការណ៍ដែលគ្រាន់តែជាសក្ខីកម្មទៅលើចំណុចជាក់លាក់, សមត្ថភាពនៃការវាយតម្លៃពីភាពអាចជឿទុកចិត្តបាន និងតម្លៃបង្ហាញផ្លូវរបស់ភស្តុតាងតាមវិធីសាកសួរបដិសាក្សី និងកាលៈទេសៈទាក់ទងនឹងការទទួលយកចម្លើយកាលពីលើកដំបូង[31]។ បើពិនិត្យទៅលើចំនួនកត្តាដែលត្រូវយកមកពិចារណា និងប្រធានបទនៃសក្ខីកម្មផ្សេងៗគ្នា មេធាវីការពារក្តីយល់ឃើញថាការស៊ើបអង្កេតត្រូវតែធ្វើឡើងមួយជំហានម្តងៗដោយមានការផ្តល់យោបល់ពីភាគីដែលរងការប៉ះពាល់ ។

១២. ក្នុងបរិបទនេះ ផ្ទុយទៅនឹងជំហរដែលប្រកាន់យកដោយសហព្រះរាជអាជ្ញា វាត្រូវតែបានសង្កត់បញ្ជាក់ឱ្យបានច្បាស់ថាការស៊ើបអង្កេតដែលធ្វើឡើងដោយ កសចស គឺពិតជាមិនបានធ្វើទៅតាមកម្មវត្ថុនៃការស្វែងរកការពិតទាក់ទងនឹងការចោទប្រកាន់ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរឡើយ ក្រៅតែពីការប្រមូលភស្តុតាងដាក់បន្ទុកប្រឆាំងជនជាប់ចោទប៉ុណ្ណោះ[32]។ ចំពោះហេតុផលខុសៗគ្នាដែលបាន

---

[30] សូមមើលវិធាន ៥ (ទាក់ទងនឹងលទ្ធភាពនៃកិច្ចសហប្រតិការផ្នែកតុលាការពីអន្តរជាតិ) វិធាន ៤១, ៤៨ និង វិធាន ៨៨ (ទាក់ទងនឹងអំណាចរបស់អង្គជំនុំជម្រះនេះដើម្បីកោះហៅសាក្សី) ។

[31] សេចក្តីសន្និដ្ឋានសាក្សី, កថាខណ្ឌទី ៣៣ ។

[32] សេចក្តីសន្និដ្ឋានសាក្សី, កថាខណ្ឌទី ៣២ ។

បញ្ជាក់រួចមកហើយ[33] ការស៊ើបអង្កេតរបស់ កសចស មិនអាចទាញយកប្រយោជន៍ពីសច្ចធារណ៍នៃអនាគតិដែលតែងតែភ្ជាប់ទៅនឹងការស៊ើបអង្កេតមុនការជំនុំជម្រះតាមច្បាប់ស៊ីវិលឡើយ[34] ។ ក៏ជាមូលហេតុដែលបានបញ្ជាក់រួចមកហើយដែរ[35] អាចនិយាយបានថា "កំណត់ស្តាប់ចម្លើយជាច្រើនដែលបានប្រមូលបាននៅមុនការចាប់ផ្តើមដំណើរការនីតិវិធីនៅចំពោះមុខ អវតក ក៏អាចជាសញ្ញាណដ៏ខ្លាំងខ្លានៃភាពអាចជឿទុកចិត្តបានដែរ ដូចជាភស្តុតាងដែលប្រមូលបានដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ឬអ្នកស្រាវជ្រាវ [...])[36]។ ទោះបីជាច្បាប់តម្រូវឲ្យធ្វើការស៊ើបអង្កេតដោយអនាគតិ មិនថាឡើយភស្តុតាងជាភស្តុតាងដាក់បន្ទុក ឬដោះបន្ទុក[37] ក៏ការស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេតមិនមានយុត្តិធម៌យ៉ាងពិតប្រាកដ ហើយដំណោះស្រាយនៅក្នុងដីកាដំណោះស្រាយ[38] មិនមានអ្វីក្រៅតែពីការប្រឌិតផ្នែកច្បាប់នោះទេ ។

១៣. ក្នុងករណីណាក៏ដោយ អង្គជំនុំជម្រះត្រូវតែធ្វើតាមករណីយកិច្ចរបស់ខ្លួនដើម្បី: ធានាឲ្យបាននូវភាពត្រឹមត្រូវនៃដំណើរការនីតិវិធី គោរពសិទ្ធិជាមូលដ្ឋានក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ អនុវត្តគោលការណ៍ស្តាបនាដែលពាក់ព័ន្ធ (favor rei) និងការវាយតម្លៃវិមតិសង្ស័យនៃភស្តុតាង (in dubio reo) និងជៀសវាងការជំនុំជម្រះក្តីក្លែងក្លាយ (paper trial) ដែលគ្រាន់តែទទួលយកការបញ្ចប់ការស៊ើបអង្កេតរបស់ កសចស ដែលមេធាវីការពារក្តីត្រូវបានទប់ស្កាត់យ៉ាងសកម្មមិនឲ្យមានតួនាទីយ៉ាងសំខាន់ក្នុងដំណើរការស៊ើបអង្កេតនេះ ។

## គ. នួន ជា ប្រហែលជាលះបង់សិទ្ធិតទល់ជាមួយបដិសាក្សីមួយចំនួន

---

[33] សូមមើលអញ្ញត្រកម្មរួម នៅកថាខណ្ឌទី៤-១៩, ៥៧-៦៥ ។

[34] សេចក្តីសន្និដ្ឋានសាក្សី, កថាខណ្ឌទី ៣១ ។

[35] សូមមើលអញ្ញត្រកម្មរួម នៅកថាខណ្ឌទី១៥ ។

[36] សេចក្តីសន្និដ្ឋានសាក្សី, កថាខណ្ឌទី ៣៩ ។

[37] សូមមើលវិធាន ៥៥(៥) ។

[38] សូមមើលវិធាន ៧៦(៧) ("លើកលែងជាកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍ ដីកាដំណោះស្រាយត្រូវតែតម្រូវឲ្យកែកំហុសនៃការមិនគោរពវិធានបញ្ញត្តិស៊ើបសួរ ។

### ទោះបីជាបដិសាក្សីទាំងនោះមានវត្តមាននៅសវនាការក៏ដោយ

១៤. តបទៅតាមការពិនិត្យសំណើណាមួយរបស់សហព្រះរាជអាជ្ញា និងការអនុម័តដោយអង្គជំនុំជម្រះ មេធាវីការពារក្តីប្រហែលជាមានលទ្ធភាពប្រាប់ឲ្យលោក នួន ជា លះបង់សិទ្ធិរបស់គាត់ក្នុងការតទល់ជាមួយបដិសាក្សីមួយចំនួន (ឧទាហរណ៍ បដិសាក្សីដែលសក្ខីកម្មរបស់ពួកគេពាក់ព័ន្ធយ៉ាងខ្លាំងទៅនឹងបទល្មើសដែលបានប្រព្រឹត្តនៅកន្លែងប្រព្រឹត្តឧក្រិដ្ឋមួយចំនួន) ដោយមិនគិតពីវត្តមានរបស់ពួកគេនៅក្នុងសវនាការឡើយ ។ ក្នុងចំណុចនេះ មេធាវីការពារក្តីនឹងស្វាគមន៍គំនិតផ្តួចផ្តើមណាមួយពីសហព្រះរាជអាជ្ញា។

## III. សេចក្តីសន្និដ្ឋាន

១៥. ដូច្នេះ ផ្អែកលើមូលហេតុដែលបានបញ្ជាក់ក្នុងចម្លើយតបនេះ មេធាវីការពារក្តីយល់ឃើញថា៖

ក. មានសិទ្ធិដាច់ខាតក្នុងច្បាប់កម្ពុជាដើម្បីសួរដេញដោលនៅលើបដិសាក្សីដែលអាចរកបានទាំងអស់នៅសវនាការ ដែលមិនត្រូវបានតទល់ដោយជនជាប់ចោទ ។

ខ. ការទទួលយកកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សីនៅពេលជំនុំជម្រះជំនួសឲ្យសក្ខីកម្មផ្ទាល់មាត់ អាចអនុញ្ញាតបានក្នុងករណីមួយចំនួនដោយផ្អែកលើលក្ខខណ្ឌដែលបង្កើតឡើងដើម្បីការពារសិទ្ធិ និងប្រយោជន៍របស់ជនជាប់ចោទ ។

គ. នួន ជា ប្រហែលជាយល់ព្រមលះបង់សិទ្ធិរបស់គាត់ក្នុងការតទល់ជាមួយបដិសាក្សីមួយចំនួន ទោះបីជាពួកគេមានវត្តមានដើម្បីផ្តល់សក្ខីកម្មនៅក្នុងសវនាការក៏ដោយ ។

ដោយសារតែបញ្ហាទាំងនេះពាក់ព័ន្ធដោយផ្ទាល់ទៅនឹងបញ្ជីឈ្មោះសាក្សី និងអ្នកជំនាញសក្តានុពលដែលបានដាក់ដោយភាគី[39] ទឡ្ហីករណ៍ផ្ទាល់មាត់បន្ថែមទៀតនៅសវនាការបឋមដែលនឹងត្រូវបន្ត[40] គឺ

---

[39] វិធាន ៨០ស្ទួន(២)

[40] សូមមើលឯកសារ **E-93/9** សម្គាល់ "សំណើសុំបន្ថែមសាក្សី និងបន្តសវនាការបឋម" ចុះថ្ងៃទី ៥ ខែ កក្កដា ឆ្នាំ ២០១១ ERN 00711970–00711975 ។

ជាការសាកសម ដូច្នេះហើយមេធាវីការពារក្តីសូមស្នើសុំឲ្យមានសវនាការបឋមបន្តទៀត។

**សហមេធាវីការពារក្តីលោក នួន ជា**

**សុន អរុណ**

Michel PESTMAN & Victor KOPPE